-ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ ដើម្បីស្វែងរកជំនួយផ្តល់អោយដំណើរការរបស់ក្រុមការងារ និងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសជំនាញដល់មន្ត្រីជំនាញ

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារជាប្រចាំខែ ត្រីមាស ជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣ :** សមាជិកគណៈកម្មាធិការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គទេសាភិបាលធនាគារជាតិកម្ពុជា ប្រធាន និងសមាជិកក្រុមការងារដែលបានរាយនាមក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## សេចក្តីសំរេច លេខ ៤៧ សសរ
## ស្តីពីការបង្កើតក្រុមការងារ
## ចំរុះមួយ ដើម្បីប្រជុំដោះស្រាយ លើលក្ខខណ្ឌសេសសល់
## ក្នុងការបំពេញអោយចប់ នូវទំរង់បែបបទនៃគំរោងការ
## សាងសង់រោងចក្រអគ្គីសនី C4 របស់ក្រុមហ៊ុន Cambodia Power

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែង

-បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីជូនដំណឹងលេខ ៩៥៩ សជណ.ឥស ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមតំរូវការចាំបាច់

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមការងារចំរុះមួយសំរាប់ប្រជុំពិនិត្យ និងពិភាក្សាលើបញ្ហានៅសេសសល់ និងលក្ខ័ណ្ឌមួយចំនួន ដើម្បីឈានដល់បញ្ចប់ទំរង់បែបបទនៃដំណើរការ វិនិយោគសាងសង់រោងចក្រអគ្គិសនី C4 របស់ក្រុមហ៊ុន Cambodia Power ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ចាំ ឃួន ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ ប្រធាន
២-ឯកឧត្តម ខូត រិន់ឌី អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
៣-ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៤-ឯកឧត្តម សួន សិទ្ធី អគ្គលេខាធិការរង CDC សមាជិក
៥-ឯកឧត្តម ឡេង ប៉េងឡុង ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
៦-ឯកឧត្តម ប្រាក់ ថៃសៀង អភិបាលរងទី២ សាលាក្រុងភ្នំពេញ សមាជិក
៧-លោកបណ្ឌិត ទី នរិន្ទ អគ្គនាយករង អគ្គិសនីកម្ពុជា សមាជិក
៨-លោកបណ្ឌិត សាត សាមី អនុប្រធាននាយកដ្ឋានថាមពល ក្រសួងឧស្សាហកម្ម សមាជិក
៩-តំណាងក្រុមហ៊ុន Cambodia Power សមាជិក
១០-លោក ស៊ុន ម៉ុណ្ណា ប្រធានការិយាល័យ IPP ( EDC) សមាជិក
១១-លោក ឈន់ សុជាតិ ប្រធានការិយាល័យ នាយកដ្ឋាន ផែនការសហប្រតិបត្តិការ លេខា

ប្រការ ២ : ក្រុមការងារចំរុះខាងលើមានភារកិច្ច ពិនិត្យ ពិភាក្សា និងផ្តល់យោបល់តាមសំណើសុំលើចំណុចនីមួយៗ របស់ក្រុមហ៊ុន ដូចខាងក្រោម

-ការអនុញ្ញាតនាំចូល Gas Naphtha ដោយរួចពន្ធ អត្រា (0%) ។
-ការអនុគ្រោះ<u>មិនយកពន្ធកាត់ទុក</u> លើការប្រាក់ របស់អ្នកផ្តល់ហិរញ្ញប្បទាន ។
-សងវិញនូវប្រាក់អាករ លើតំលៃបន្ថែម (VAT)
-ចេញច្បាប់អនុញ្ញាត ផ្តល់សិទ្ធប្រើប្រាស់ដីដែលជាកម្មសិទ្ធិសាធារណៈ ក្នុងការជីកកប់ និងប្រើប្រាស់ បំពង់បង្ហូរទឹក ពីមាត់ទន្លេ ទៅកាន់រោងចក្រ C4 ក្នុងរយៈពេលនៃកិច្ចព្រមព្រៀង (PPA) ។
-ដោះស្រាយការសាងសង់ផ្លូវរថភ្លើង សំរាប់ដឹកជញ្ជូន Gas Naphtha ចូលក្នុងរោងចក្រអគ្គិសនី C4 ។
-សំរបសំរួល លើបញ្ហាបច្ចេកទេស ដែលស្នើឡើងដោយអគ្គិសនីកម្ពុជា ។
-តាមដានក្នុងការជំរុញអោយបានសំរេចនូវ អនុសញ្ញាអង្គការសហប្រជាជាតិ ទីក្រុងញូវយ៉ក (New York Convention ) ស្តីពីការទទួលស្គាល់ និងប្រតិបត្តិសេចក្តីសំរេចរបស់មជ្ឈត្តការបរទេស ។
-និងបញ្ហាពាក់ព័ន្ធផ្សេងៗ
-ធ្វើរបាយការណ៍លើករណីស្នើសុំនីមួយៗក្រោយពេលចប់អង្គប្រជុំ ស្តីពីលទ្ធផលដំណើរការសំរបសំរួល ពិនិត្យនិងពិភាក្សាលើការបញ្ចប់ទំរង់បែបបទ ដំណើរការសាងសង់រោងចក្រអគ្គិសនី C4 ជាជំហានៗ

ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងអនុម័តការដោះស្រាយបំណុលទាំងស្រុង មួយខែមុនពេលផុតសុពលភាព គឺថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០០ ។

**ប្រការ ៣ :** ប្រធានក្រុមការងារធំ មានភារកិច្ចអញ្ជើញសមាជិកក្រុមការងារ ព្រមទាំងតំណាងក្រសួង១ មកប្រជុំ តាមតម្រូវការ និងពេលវេលាកំណត់ដោយអង្គប្រជុំ ។

**ប្រការ ៤ :** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អគ្គិសនីកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សាលាក្រុងភ្នំពេញ ប្រធាន និងសមាជិក ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***